# តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ




## តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ ?

ខ្មែរទូទៅ តែងតែទុក ថ្ងៃទី៧ មករា ជា ការរាតត្បាតចេញមុខ ដោយកម្លាំងយោធា ពីសំណាក់យៀកណាម មកលើ ប្រជាជាតិខ្លួន។ ការរាតត្បាតនេះ ជាអំពើ ឈ្លានពានមួយ ដែលគ្មានអ្នកណាមួយ អាចប្រកែកបាន។ អំពើនេះ បានត្រូវសហគមន៍អន្តរជាតិ គេធ្វើការផ្តន្ទាទោសទាំងស្រុង ហើយគេនាំគ្នា ធ្វើបច្ចាប័នសេដ្ឋកិច្ច ទៅលើ ប្រទេសយៀកណាម ឥតរួញរា។ គេទុកយៀកណាម ជាអ្នកឈ្លានពានកម្ពុជា ដោយរំលោភ លើច្បាប់អន្តរជាតិ ទោះបី យៀកណាម ទុកអន្តរាគមន៍ របស់ខ្លួន ជាជំនួយដល់ រណសិរ្សខ្មែរ រណបខ្លួន ដើម្បី រំដោះប្រជាជនខ្មែរ ពីរបបប្រល័យពូជសាសន៍ ដែលមាន ឈ្មោះថា ‹កម្ពុជាប្រជាធិបតេយ្យ›។ យើងដឹងថា ទណ្ឌកម្ម របស់សហគមន៍អន្តរជាតិ ទៅលើ ប្រទេសយៀកណាមនេះ វាផ្អែកទាំងស្រុងទៅលើ ច្បាប់អន្តរជាតិ ដែលជា មូលដ្ឋានសំខាន់ សំរាប់រកដំណោះស្រាយ ក្នុងជម្លោះ រវាង ប្រទេសមួយ នឹងប្រទេសមួយ ដែលជា សមាជិកនៃ អង្គការសហប្រជាជាតិ (អ.ស.ប.) ដែលមាន តុលាការយុត្តិធម៌អន្តរជាតិ (CIJ) ជា អង្គការ សំរាប់រកដំណោះស្រាយតាមផ្លូវសន្តិភាព និង យុត្តិធម៌ ដូចមាន ចែងក្នុង មាត្រា ទី៩២ នៃ កតិកាសញ្ញា របស់ អ.ស.ប។ ដូច្នេះ ទណ្ឌកម្ម នៃ អ.ស.

# តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ

ប. នេះ វាមាន លក្ខណៈ ដែរជា សេចក្ដីថ្លែងការណ៏ នូវ គោលការណ៏ នៃ ច្បាប់អន្តរជាតិ ដែលជា គោលការណ៏ តម្រូវ ឲសមជិកខ្លួននិមួយៗគោរព ជាដាច់ខាត។ តែយើងដឹងថា យៀកណាម ទុកទណ្ឌកម្មនេះជារឿងឥតបានការ ហើយគេបន្ត នយោបាយគេ ពីឋានៈជា ឧបត្ថម្ភក  នៃ រណសិរ្សខ្មែរ រំដោះប្រជាជនខ្មែរ ក្លាយជា កងកម្លាំង កាន់កាប់ ប្រទេសកម្ពុជា តែម្ដង។ យើងអាចសួរ ជាសំណួរថា នៅពេលនោះ តើហេតុអ្វី បានជា សហគមន៏អន្តរជាតិ គេមិនព្រមលើកយក ផ្នែកសីលធម៌ មកបង្ហាញឲឃើញថា អន្តរាគមន៏យៀកណាម ជា ការសង្គ្រោះ នៃ ប្រជាពលរដ្ឋខ្មែរ ? ដូចយើង បានរៀបរាប់ខាងលើ រួចមកហើយ ក្រោយពីបាន វាយបំបែក កងទ័ពកម្ពុជាប្រជាធិបតេយ្យរួចហើយ កងទ័ពយៀកណាម មិនព្រមដក ទ័ពចេញពី កម្ពុជានោះទេ។ ហេតុនេះឯង អន្តរាគមន៏ នៃ កងទ័ពយៀកណាម គ្មានមាន ស្ថានសម្រាលទោស នៃ សីលធម៌ អ្វីមួយឡើយ ក្រៅតែវាមាន លក្ខណៈ ជា អំពើឈ្លានពាន ចេញមុខសុទ្ធសាធ មកលើស្រុកខ្មែរ។ ម៉្យាងមួយវិញទៀត ការខ្វះ នៃ អង្គការ នៃ យុត្តិធម៌អន្តរជាតិ នៅពេលនោះ (គួរដឹងដែរថា តុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI, ICC) មិនទាន់មាននៅឡើយ ព្រោះតុលាការនេះ ត្រូវគេបង្កើតឡើង នៅ ថ្ងៃទី១ កក្កដា ឆ្នាំ ២០០២ ដែលជាតុលាការអន្តរជាតិ សំរាប់កាត់ទោស អ្នកដឹកនាំរដ្ឋ ឬ បុគ្គលណា ដែលបានប្រព្រឹត្តអំពើ ប្រឆាំងនឹង មនុស្សជាតិ ឬ ប្រព្រឹត្តបទឧក្រិដ្ឋក្នុងសង្គ្រាម) ធ្វើឲ អ.ស.ប. គ្មានលទ្ធភាពនឹង ធ្វើ

## តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ

ការផ្តន្ទាទោស ដល់អ្នកដឹកនាំ រដ្ឋកម្ពុជាប្រជាធិបតេយ្យ ពីបទ ប្រព្រឹត្ត អំពើប្រល័យពូជសាសន៍ ដែលជា ការពន្យាពេលមួយ ៖ ពួកអ្នកដឹកនាំទាំងនោះ បានរស់ជា ជននិទ្ទណ្ឌ នៅចំពោះ អំពើឧក្រិដ្ឋកម្ម ដែលខ្លួន បានប្រព្រឹត្ត ទៅលើ ប្រជាជនខ្លួន ឯង ដែលមាន អ្នករងគ្រោះ ចំនួនប្រមាណជាង ២លាន នាក់។ មិនតែប៉ុណ្ណោះ របបកម្ពុជាប្រជាធិបតេយ្យនេះ នៅតែមាន តួ នាទី ជាតំណាងរដ្ឋខ្មែរ និង ប្រជារាស្ត្រខ្មែរ ដែលជា អ្នករង គ្រោះ នៃអំពើ ប្រល័យពូជសាសន៍ របស់ខ្លួន អស់រយៈពេល ១២ ឆ្នាំ (១៩៧៩-១៩៩១) នៅ អ.ស.ប.។ យើងអាចសួរទៀតដែរថា ពេលនោះ ហេតុអ្វីក៏ អ.ស.ប មិនបង្កើតតុលាការ បែប តុលាការ ‹Nuremberg› ដើម្បី កាត់ទោស ពួកអ្នកដឹកនាំខ្មែរ ក្រហម ដូចគេបាន កាត់ទោស អ្នកដឹកនាំ របប ‹ណាស៊ី› នៅ ប្រទេសអាឡឺម៉ាញ។ យើងដឹងហើយថា តុលាការ ‹Nuremberg› គឺ អ្នកឈ្នះសង្គ្រាម គេបានបង្កើត សំរាប់កាត់ ទោស អ្នកចាញ់ សង្គ្រាម ឯចំណែក នៅក្នុងករណីខ្មែរវិញ អ្នកឈ្នះគឺជា អ្នក ល្មើសច្បាប់ ឯអ្នកចាញ់ជា ឃាតករ និង ជា អ្នករងគ្រោះផង ដូច្នេះឯង ការបង្កើតតុលា បែបតុលាការ ‹Nuremberg› នេះ វា ពុំអាចធ្វើបាន សំរាប់ករណីខ្មែរយើងនេះ។ ការនេះ វាពិតជា ការមិនទំនង ណាស់ទៅហើយ សំរាប់ប្រជាពលរដ្ឋខ្មែរ ដែលជា ជនទទួល នូវ ការរងគ្រោះពីរយ៉ាង :

១. ពីការឈ្លានពានបរទេស,

២.ពីរបបប្រល័យពូជសាសន៏។

តែរឿងនេះ យើងទុកវា មួយគ្រាសិនចុះ ព្រោះជារឿងកើត អន្តែងអន្តៃ (មិនចេះចប់) ក្នុងមជ្ឈដ្ឋាន អ្នកចេះដឹងខ្មែរ។ ទីនេះ យើងចង់ ពិនិត្យ តែពី ការទទួលខុសត្រូវខ្មែរយើងផ្ទាល់ អំពីថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ព្រោះយើងយល់ថា ការរក នៃ ការពិតនេះ វាជា មេរៀន សំរាប់អនាគត ដែលយើង ធ្លាប់ឮ ពាក្យចាស់បុរាណ លោកថ្លែងថា : ‹ទោសខ្លួនឯង មើលមិនយល់ ទោសគេ ចសោតសល់ រមិលយល់ ប៉ុនទាំងភ្នំ›។

**ការស្មានទី១ : បើទុកខ្លួនយើងជាអ្នករងគ្រោះ នៃ របបខ្មែរក្រហម :**

យើងជាខ្មែរ ក្នុងចំណុចនេះ យើងអាច ទុកថ្ងៃទី៧ មករា ជាការចំអក លើវាសនាខ្លួន ព្រោះខ្លួន បានរួចជីវិត ដោយសា កងទ័ពយួន ដែលនាំអោយ ខ្មែរអ្នករងគ្រោះ នៃ របបខ្មែរក្រហមមួយចំនួន តែងគិតក្នុងចិត្ត ដើម្បី រំងាប់ មហាទុក្ខដោយអនុលោម តាមធម៌ព្រះពុទ្ធ ថា ជ័យជំនិះយៀកណាមនេះ ជាកម្មផល របស់ពលរដ្ឋខ្មែរ ដែលខ្លួន ត្រូវទទួលយក ដោយផ្លូវចត់ជាទីបំផុត ឯចំណែក អ្នកខ្លះគិតថា ខ្លួនកើតជា មនុស្សតែងតែ ចង់រស់ ទោះបី ការរស់នៅថ្មី ក្រោមអំណាច យៀកណាម មានសភាពជា ការរស់នៅជាងហិរិភាព (សេចក្តីខ្មាស) ក៏

ដោយ តែវា នៅតែប្រសើរជាង ការរស់នៅជា បសុសត្វ ត្រូវពួកក្មេងឈ្លបខ្មែរក្រហម យកទៅសម្លាប់ តាមចំណង់ចិត្ត។ គំនិតនេះជា ការគិតមួយរំពេញ របស់អ្នករងគ្រោះក្រោយពី ដឹងខ្លួនថា បានរួចប្រាកដពី សេចក្តីស្លាប់នោះឯង។ យើងជា មនុស្សពុំអាច ក្នុងនាមជា អ្នកជាតិនិយមក្តី បន្ទោស បងប្អូនខ្មែរ ជាអ្នករងគ្រោះ ដែលគាត់ បានគិតបែបនេះឡើយ ព្រោះគំនិតនេះជា ប្រតិកម្មជា ធម្មជាតិ របស់មនុស្សតែប៉ុណ្ណោះ។ ក្នុងចំណុចនេះ យើងលើកទ្រឹស្តី សង្គមសាស្ត្រមួយ របស់អ្នកប្រាជ្ញអាមេរិកាំងម្នាក់ ឈ្មោះលោក Maslow (Maslow's hierarchy of needs) មកជូនជា ឧទាហរណ៍។ ទ្រឹស្តីនេះ គេឲឈ្មោះថា : សេចក្តីត្រូវការ ៥យ៉ាង របស់មនុស្ស :

១. សេចក្តីត្រូវការ នៃ អាហារ សំរាប់បរិភោគ,

២. សេចក្តីត្រូវការ នៃ សុវត្ថិភាព,

៣. សេចក្តីត្រូវការ នៃ ការរាប់អានជា ការសរសើរ ពីអ្នកដទៃ,

៤. សេចក្តីត្រូវការ នៃ ការចូលរួមចំណែក ក្នុងសកម្មភាព ណាមួយ ក្នុងសង្គម,

៥. សេចក្តីត្រូវការ នៃ មាបនកម្ម (ការបង្កើត) ដោយខ្លួនឯង។

## តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ

សេចក្តីត្រូវការទាំង៥យ៉ាងនេះ វាជា សេចក្តីត្រូវការ ដែលមានកំរិតឡើងរៀងពី មួយទៅមួយ របស់មនុស្ស រស់នៅ ក្នុងសង្គមមួយ។ យើងដឹងថា ក្នុងរបបខ្មែរក្រហម ប្រជារាស្ត្រខ្មែរ មាន សេចក្តីត្រូវការ តែមួយគត់ គឺ អាហារ សំរាប់បរិភោគ។ នៅពេលដែល របប បង្អត់បាយនេះ ត្រូវបានកងទ័ពយួនវាយបែក ជាកំទេចទៅ ប្រជារាស្ត្រខ្មែរ គាត់មើឃើញ តែមួយគត់ ក្នុងបរាជ័យពួកខ្មែរក្រហមនេះ គឺ ការសង្ឃឹមនឹងមាន អាហារសំរាប់បរិភោគតែប៉ុណ្ណោះ ព្រោះពេលនោះគាត់មានកម្លាំងប្រាថ្នាឯណានឹងគិត រកសេចក្តីត្រូវការ ដទៃទៀត ដែលបានរៀបរាប់ខាងលើ ជាពិសេសគំនិត ស្នេហាជាតិ ក្នុងពេលដែលពោះគាត់ដាច់បាយ អស់រយះពេលជាង៣ឆ្នាំ រួចមកហើយ។ យើងត្រូវយល់ថា ការនេះ វាជាធាតុ របស់មនុស្សលោក : ‹បរិភាគឆ្អែតសិន ទើបអាច មានគំនិត គិតឃើញអ្វីតទៅទៀត› ពេលដែលប្រជាជនខ្មែរ អត់បាយ នៅពេលគាត់ ឃើញ ទាហានយួន ដេញបាញ់យោធាខ្មែរក្រហាម គាត់ឥតបានមើលឃើញ អ្វីទាំងអស់ ព្រោះ ក្នុងគំនិតគាត់ គឺ គាត់រំអុក តែបញ្ហាក្រពះគាត់តែប៉ុណ្ណោះ។ ពេលទាហានយួន អនុញ្ញាតឲគាត់ មានលទ្ធភាព រកអាហារបរិភោគរៀងៗខ្លួនបាន ចំពោះគាត់ លទ្ធភាពនេះ គឺជាអំពើសង្គ្រោះនោះឯង។ យួនមិនយួន ជាអ្នករំដោះគាត់ ជារឿងចាំគិត នៅពេលឆ្អែតបាយសិន។ នេះជាការពិតមួយ ដែលខ្មែរយើង ពុំអាចគេចកែបាន ទោះបី ការពិតនេះ វាមានភាពឃោឃៅមួយ ក្នុងសតិខ្មែរយើងក៏ដោយ។ តែជា អកុសលរបស់ប្រជា

## តើថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ

ពលរដ្ឋខ្មែរ។ តែត្រូវដឹងដែរថា ក្នុងរយៈពេល មួយសទវត្ស (១៩៧៩-១៩៨៩) ដែលយួនកុម្មុយនិស្ត ត្រួតត្រា នៅស្រុកខ្មែរ ពួកគេ នៅតែ បន្ត នយោបាយ បង្អត់បាយ ប្រជារាស្ត្រ គឺធ្វើយ៉ាងណាឲរាស្ត្រខ្មែរ រស់នៅក្នុង សេចក្តីត្រូវ នៃ ការអាហារ សំរាប់បរិភោគជានិច្ច។ របៀបធ្វើខុស ពីខ្មែរក្រហមគឺ គេឲខ្មែរ បរិភោគ ក្នុងកំរិតអប្បបរិមាណ សំរាប់រស់ ពីមួយថ្ងៃទៅមួយថ្ងៃតែប៉ុណ្ណោះ ដែលជា កត្តាមួយ មិនអាចឲ ខ្មែរ អាចមាន លទ្ធភាព ស្វែងរក សេចក្តីត្រូវការទី២គឺ សេចក្តីត្រូវការ នៃ សុវត្ថិភាព ដែលជា ស្ពានឆ្លងទៅរក សេចក្តីត្រូវការបន្តៗទៅទៀត។ យើង ឃើញច្បាស់ទៅទៀតថា សព្វថ្ងៃនេះ ទោះបី យើងឃើញមាន អភិវឌ្ឍន៍ នៅស្រុកខ្មែរ ដែលយើ អាចទុកជា អាការៈក្រៅ នៃ សេចក្តីជឿនលឿន តែការពិត ខ្មែរ ភាគច្រើនបំផុត គាត់នៅតែ រស់ជានិច្ច ក្នុងសេចក្តីត្រូវការទី១ គឺសេចក្តីត្រូវការ នៃ អាហារបរិភោគ។

ក្នុងស្ថានភាពនេះ ដែលនាំឲយើង ធ្វើសន្និដ្ឋានបានថា ហាក់បីជា ចេតនាមួយ របស់របបនយោបាយបច្ចុប្បន្ន ធ្វើឲខ្មែរ គិតតែខ្វល់ខ្វាយពី បញ្ហាក្រពះ ឥតមាន ពេលវេលា គិតអ្វីក្រៅពីរឿងនេះឡើយ។ ដូច្នេះ ការរងគ្រោះ ក្នុងរបបខ្មែរក្រហម នៅតែមាន បន្ត មកដល់បច្ចុប្បន្នកាលនេះទៀត វាគ្រាន់តែមានរូបភាព ខុសគ្នាតែប៉ុណ្ណោះ តែគ្រោះថ្នាក់ សំរាប់ប្រជារាស្ត្រខ្មែរ នៅមានដដែល។ តើអ្វីខ្លះទៅ ដែលយើងអាច ដកស្រង់ពីការពិនិ

ត្យនេះ ? គឺ អកម្មភាព របស់ប្ររាស្ត្រខ្មែរ នៅចំពោះមុខគ្រោះថ្នាក់ខ្លួននោះឯង។ ការនេះ ជាការទទួល នៃ ការខុសត្រូវរួមមួយ របស់ខ្មែរយើង។

**ការស្មានទី២ : បើប្រជាជាតិខ្មែរជា ប្រទេស មានការទទួលខុសត្រូវ លើជោគវាសនា របស់ខ្លួនឯង :**

យើងជាខ្មែរ ក្នុងចំណុចនេះ យើងអាចចាត់ទុក ថ្ងៃទី៧ មករា ជាលទ្ធផល នៃ នយោបាយ ភាន់ច្រឡំ របស់អ្នកដឹកនាំខ្មែរ យើងគ្រប់ជំនាន់។ ទុព្វល (កម្លាំងថយខ្សោយ) ស្រុកខ្មែរ គឺត្រូវ ចាំបាច់ មានអ្នកទទួលខុសត្រូវ នៅក្នុងនគរ មុនសិន មុន នឹងរកមុខ អ្នកទទួលខុសត្រូវ ពីក្រៅនគរ ហេតុអ្វី ?

ព្រោះថា បើខ្មែរយើង ជឿជាក់ពិតថា ប្រទេសខ្លួន ជាប្រទេស ធ្លាប់ មានអនុភាព ដូចនេះ យើងត្រូវសួរ ខ្លួនឯងថា អ្វីខ្លះទៅ ជាមូលហេតុ នៃ ទុព្វលខ្មែរ ? យើងតែងតែយក ការឈ្លានពាន ពីសំណាក់ ប្រទេសជិតខាង ទុកជា មូលហេតុ សំខាន់បំផុត។ មូលហេតុនេះ ពិតជាមាន តែវាមិនទាន់គ្រប់គ្រាន់ សំរាប់ បង្ហាញ នូវ អត្តង្គតខ្មែរបានទាំងអស់នោះឡើយ ដូចយ៉ាង មានខ្មែរយើងខ្លះ រហូតគិតទៅទៀតថា មិនមែន ពួកខ្មែរ ក្រហមទេ ជាអ្នកសម្លាប់ ប្រជារាស្ត្រខ្មែរ ចំនួនប្រមាណជាង លាននាក់ គឺពួកយួនទេ ជាអ្នកសម្លាប់ ព្រោះពួកយួន លួច

បង្អាប់ ពួកវា នៅក្នុងជួរ ពួកខ្មែរក្រហម។ ការគិតបែបនេះជាការគិត មិនមាន ការទទួលខុសត្រូវ ទុកឲ អ្នកដឹកនាំជាតិជំនាន់នោះ ដែលជា អ្នកទទួលខុសត្រូវ រួចខ្លួន ឥតមាន ការទទួលខុសត្រូវ ក្នុងវិនាដកម្មជាតិទៅវិញ ដូចគ្នានឹងការស្ម័គ្រខ្លួន បំរើប្រយោជន៍យួនកុម្មុយនិស្ត របស់សម្តេចសីហនុ នៅក្នុងសង្គ្រាម ចន្លោះ ឆ្នាំ ១៩៧០ ដល់ ១៩៧៥ និង ជួយរបបរណបយួនបច្ចុប្បន្ន ឲអាចរក្សា អំណាចផ្តាច់ការ បានតាំងពីឆ្នាំ ១៩៩៣ មកដល់ ឥឡូវនេះ។ បើខ្មែរយើងនាំគ្នា គិតថា មានតែ យៀកណាម ឬ សៀម ជាកត្តា នៃ អត្តឃាតខ្មែរ គឺហាក់បីដូចជា យើងយល់ ឃើញថា គ្មានខ្មែរណាម្នាក់ ជាអ្នកទទួលខុសត្រូវនោះឡើយ។ ភាពគ្មានទំនង នៃ គំនិតនេះ គឺពិតជាកត្តា នៃ អត្តឃាតខ្មែរ មួយដែរ ហេតុនេះឯងបានជាយើង ធ្វើការពិចារណារ អំពី ការទទួលខុសត្រូវ របស់អ្នកដឹកនាំខ្មែរ ក្នុងបញ្ហាជាតិ ដែលមាន សេចក្តី ដូចខាងក្រោមនេះ។

១. លោក លន់ នល់ ជាអ្នកទទួលខុសត្រូវ ព្រោះ គេ ចោទលោកថាជា អ្នកនាំ បង្កើតសង្គ្រាម ជាមួយយួនកុម្មុយនិស្ត ដែលវាមាន កងទ័ព នៅក្នុងស្រុកខ្មែរ ចំនួន ៦ម៉ឺននាក់ ? ឧបមាថា លោក លន់ នល់ ជាអ្នកទទួលខុសត្រូវ ក្នុងឋានៈលោក ជានាយករដ្ឋមន្ត្រី។ តែបើយើង លើកយក ធាតុសង្គ្រាម មកពិនិត្យមើល យើងឃើញថា សង្គ្រាមនេះ មិនមែនខ្មែរយើងទេ ជាអ្នកបង្ក គឺយួនកុម្មុយនិស្ត ជាអ្នកវាយប្រហារខ្មែរយើងមុន តែ

ម្តង ហើយ គតទាំងមាន ធ្វើការប្រកាស ជាមុននោះផង។ ចំណុចនេះហើយ ដែលនាំឲយើង ពិបាកចាត់ទុកថា ជាការទទួលខុសត្រូវ របស់លោក លន់ នល់ ព្រោះគាត់ មិនមែន ជាអ្នកបង្កើតសង្គ្រាម តែអ្នកចោទ គេអាចចោទ បន្តទៀតថា លន់ នល់ មិនមែនជា អ្នកបង្កើតសង្គ្រាម តែគាត់ ជាអ្នកបង្កសង្គ្រាម ព្រោះគាត់ ជាអ្នកបង្ករឿង ទម្លាក់ សម្តេចសីហនុ ពីដំណែង ប្រមុខរដ្ឋ អស់មួយជីវិត ដែលជា កត្តា នាំបង្កើត សង្គ្រាម។

ឧបមាថា ការចោទនេះ មានលក្ខណ: ត្រឹមត្រូវពិត តែយើងសួរទៅអ្នកចោទវិញថា រឿងទម្លាក់ សម្តេចសីហនុនេះ វាមាន ការទាក់ទងអ្វីនឹងយួនកុម្មុនិស្ត ដែលជាបរទេសសុទ្ធ តែនាំគ្នាគេលើករេហ៍ពល សន្ធឹកគឹកកង មកវាយប្រហារ កងទ័ពខ្មែរទៅវិញ ? រឿងទម្លាក់ សម្តេចសីហនុ ជារឿង ខ្មែរនឹងខ្មែរ មិនមែនជារឿង ខ្មែរនឹងយៀកកុង នោះឡើយ។ ដូច្នេះលោក លន់ នល់ មិនអាច ជា អ្នកទទួលខុសត្រូវ ក៏ដូចជា ប្រជាពលរដ្ឋខ្មែរដែរ ចំពោះមុខសង្គ្រាមមួយ ដែលយួនកុម្មុនិស្ត ជាអ្នកបង្កើត ដោយមាន ការគាំទ្រចេញមុខ ពីសម្តេចសីហនុ។ តែទោះបីលោក លន់ នល់ មិនមាន ការទទួល ខុសត្រូវ ក្នុងរឿងសង្គ្រាមនេះ តែគាត់ និងអ្នកដឹកនាំ របបសាធារណ:រដ្ឋ ត្រូវមាន ការទទួលខុសត្រូវមួយផ្នែកធំ ក្នុងឋានៈ ជាអ្នកដឹកនាំជាតិ ក្នុងកង្វះ នៃ គំនិតរៀបចំអនាគត (Préparer l'avenir) ជាតិ ឲបាន

ល្អ។ ជាបឋមគឺ ការរៀបចំ ធ្វើសង្គ្រាម តស៊ូប្រឆាំងនឹង ការឈ្លានពានយួនកុម្មុយនិស្ត និង ខ្មែរក្រហម។ ខ្វះលទ្ធភាពរៀបចំសង្គមថ្មី ក្នុងនោះ មានអំពើពុករលួយ ដែលជា ជម្ងឺមហារីកមួយ របស់ជាតិខ្មែរ។ ទោះបី អ្នកការពារ របបសាធារណៈរដ្ឋ គេនិយាយ ការពារថា ដោយសារមានសង្គ្រាម បានជាអ្នកដឹកនាំ គ្មានពេលរៀបចំសង្គមខ្មែរថ្មី ឲស្របទៅនឹង បាវចនា របស់របបសាធារណៈរដ្ឋ ដែលមាន ដូចតទៅ: សេរីភាព

សមភាព ភាតរភាព វឌ្ឍនធម៌ និង សុភមង្គល។ សេចក្តីដោះសានេះ ដោយយក កត្តា សង្គ្រាម មកធ្វើលេសនេះ រិតតែបង្ហាញ នូវ កង្វះ នៃ គំនិតរៀបចំ នៃ អនាគតជាតិ បន្ថែមទៅទៀត ព្រោះ ក្នុងសង្គ្រាមនេះហើយ ដែលអ្នកដឹកនាំ ត្រូវបង្ហាញ នូវ សមត្ថភាពខ្លួន ឥតខ្ចោះ និង មានះខ្លួន ឥតរួញរា ដើម្បីទុកជា សេចក្តីសង្ឃឹម សំរាប់ប្រជាពលរដ្ឋ ក្នុងកាលៈទេសៈ ដ៏ពិសេសនេះ។ អ្នកដឹកនាំ តាមធម្មតា ជា អ្នកទទួលខុសត្រូវ នៃគ្រប់បញ្ហាជាតិ។

២. លើកយក ករណី សម្តេចសីហនុ មកនិយាយម្តង តើទ្រង់មាន ការទទួលខុសត្រូវ បែបណាដែរ ក្នុងរឿង ប្រទេសជាតិជាប់ក្នុងទ្រូ នៃយុទ្ធសាស្ត្រ យួនកុម្មុយនិស្តមកដល់សព្វថ្ងៃនេះ ? ក្នុងការ រកសេចក្តីពិតនេះ យើងគ្រាន់តែ លើកយកមកបង្ហាញទីនេះ នូវ គោលការណ៍ នៃ នយោបាយ របស់សម្តេចសីហនុ ដែល ទ្រង់ បានយកមកធ្វើជា ផ្លូវនយោបាយ របស់ព្រះ

អង្គ គឺ ‹យក អនាគត នៃ ប្រទេសជាតិ មកធ្វើជា ការភ្នាល់› (Parier sur l'avenir) របស់ព្រះអង្គ។ យើងដឹងថា ការភ្នាល់ជាជូតកម្ម (ល្បែងស៊ីសង) មានចាញ់ មានឈ្នះ។ ឧទាហរណ៍ ដូចជាការភ្នាល់ សំរាប់អនាគត របស់ព្រះអង្គ ក្នុងនយោបាយ របស់ព្រះអង្គ ចូល ចិន យួន កុម្មុយនិស្ត។ យើងឃើញថា ការផ្នាល់នេះ សំរាប់ព្រះអង្គផ្ទាល់ វាមាន ជួនកាលចាញ់ ជួនកាលឈ្នះ តែព្រះអង្គឥតបានគិតថា ក្នុងការភ្នាល់នេះ អ្នកចាញ់រហូតគឺ ប្រជាពលរដ្ឋខ្មែរ ឯណោះទេ ព្រោះជា អ្នកបានទទួល នូវ មហាទុក្ខគ្រប់បែបយ៉ាង ក្នុងនយោបាយ នៃ ការភ្នាល់ ជាល្បែងស៊ីសងនេះ។ ចំណុចនេះហើយ ជាការទទួលខុសត្រូវ ដ៏ធំមួយ របស់សម្តេចសីហនុ ក្នុងឋានៈ ព្រះអង្គ ជាអ្នកដឹកនាំជាតិម្នាក់ ក្នុងរយៈពេលដ៏យូរអង្វែងមួយ (១៩៤២-២០១២)។ ៧០ឆ្នាំ នៃ អត្ថិភាពរបស់ព្រះអង្គ លើឆាកនយោបាយខ្មែរ នាំមក នូវ មហាទុក្ខ ដល់ប្រជារាស្ត្រខ្មែរ ធំបីយ៉ាង :

១. នយោបាយ នាំ យួនកុម្មុយនិស្ត ឲមកឈ្លានពានស្រុកខ្មែរ (១៩៧០-១៩៧៥),

២. នយោបាយ ប្រល័យពូជសាសន៏ របស់ពួកខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលជា កល្យាណមិត្ត ជាមិត្រទ្រុះផង របស់ព្រះអង្គ,

៣. នយោបាយ ជួយឧបត្ថមដល់ អ្នកដឹកនាំខ្មែរ រណបយួន ឲរស់ ក្នុងអំណាច ដើម្បី បំរើនយោបាយយៀកណាម ជាការនាំ ឲខូចប្រយោជន៍ជាតិខ្មែរ។

បើនិយាយពី ពួកខ្មែរក្រហម ដែលមាន ប៉ុល ពត ជាមគ្គុទ្ទេស នោះ ការទទួលខុសត្រូវ វាមាន ជាក់ស្តែងណាស់ ក្នុងទំហំ នយោបាយ កម្ទេចកម្លាំងជាតិ ឲរលាយសូន្យ ដែលជា កត្តាមួយ ឲយួនកុម្មុយនិស្ត ងាយស្រួលនឹង អនុវត្ត នូវ នយោបាយ វាតទឹកដីរបស់គេ។ រយះពេលពាន្ធាំ ដែល ពួកខ្មែរក្រហម បិទទ្វារ ស្រុកខ្មែរ ដើម្បីសម្លាប់ប្រជាពលរដ្ឋខ្លួនឯង គឺជា សេចក្តីសង្ឃឹម របស់យៀកណាមមួយ ដែលមាន តម្លៃអស្ចារ្យ ដែល ឥតមានបានគិតទុកផង សំរាប់ប្រយោជន៏គេ។ និទ្ទណ្ឌភាព នៃ បទឧក្រិដ្ឋ របស់ពួកខ្មែរក្រហមនេះ ជា ការអនុញ្ញាត ឲពួក អតីតឃាតកទាំងនោះមាន មុខនាទី ក្នុងថ្នាក់អ្នកដឹកនាំ ជាតិរហូតមកដល់សព្វថ្ងៃ នេះ។ ឧទាហរណ៏ជាក់ស្តែងគឺ ខ្មោច សម្តេចសីហនុនេះឯង មិនត្រឹមតែបានរួចទោស ពីបទឧក្រិដ្ឋ កម្ម ថែមទាំង មានងារជា វិរបុរសជាតិទៅទៀត។ នេះឯង ហើយ ដែលទុកជា សីលធម៌ ក្នុងសង្គមខ្មែរថ្មី ! ទីនេះ យើង មិន ចាំបាច់ស្វែងរក ការទទួលខុសត្រូវ របស់ពួកអ្នកដឹកនាំជាតិ បច្ចុប្បន្ននោះទេ ពីព្រោះពួកនោះមានខ្លួនជាខ្មែរ តែមានចិត្ត ជាយួន ដែលយើងឲឈ្មោះថាជា ‹ខ្មែរយួន› នាំគ្នារួមជាមួយ

ពួក ‹យួនខ្មែរ› (យួន មានអត្តសញ្ញាណជាតិជាខ្មែរ) បំរើ យៀក ណាម ដែលជាមាតុភូមិ របស់គេ ដើម្បី ប្រយោជន៍យៀកណាម។

ដូចបានរៀបរាប់ខាងលើនេះ យើងអាច សន្និដ្ឋានបានថា អ្នកដឹកនាំខ្មែរ មានការទទួលខុសត្រូវរួមគ្នា ចំពោះ ថ្ងៃទី៧ មករា តែកំរិត ការទទួលខុសត្រូវ មានខុសគ្នា ព្រោះ ធាតុ នៃ ការភាន់ច្រឡំ ក្នុងនយោបាយដឹកនាំជាតិ មានខុសគ្នា។ ចំពោះ លោល លន់ នល់ មានកំហុស ត្រង់លោក ខ្វះសមត្ថភាព គ្រប់គ្រាន់ សំរាប់រៀបចំ អនាគតជាតិ នៅចំពោះមុខខ្មាំងសត្រូវ របស់ជាតិគឺ យួនកុម្មុយនិស្ត។ ចំណែក សម្តេចសីហនុ កំហុស របស់ទ្រង់ ជាកំហុស ចូលខ្មាំង ដើម្បីបំផ្លាញជាតិខ្លួនឯង ដែលគេចាត់ទុកជា អំពើក្បត់ជាតិមួយ។ ឬឯពួកខ្មែរក្រហម កំហុស ពួកវាគឺ ជាកំហុស ផ្ទាក់បទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិ និងក្បត់ជាតិខ្លួនឯងផង។ បើនិយាយ អំពីកំហុស របស់ពួកអ្នកដឹកនាំសព្វថ្ងៃវិញ គឺជា កំហុសស្មើនឹង ពួកខ្មែរក្រហម ចំពោះជនណា ដែលជា អតីតក្របខណ្ឌខ្មែរក្រហម ហើយបានចូលរួម យ៉ាងសកម្ម ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរ ឯចំណែកអ្នកឯទៀត គឺមាន កំហុស ចូលដៃខ្មាំង ជាបរទេស ដើម្បី បំផ្លាញនូវ ប្រយោជន៍ជាតិខ្មែរ ដែលជា អំពើក្បត់ជាតិមួយនោះដែរ។ តែកំហុស អ្នកដឹកនាំខ្មែរ គ្រប់ជំនាន់នោះ ទោះវានៅក្នុងកំរិតណាក៏ដោយ គឺសុទ្ធ ជា នាសនៈ (សេចក្តីវិនាស) នៃ ប្រជាជាតិខ្មែរ។ កំហុស ជា ទុប្បញ្ញា (សំពីក) និមួយៗ គឺជា ជំហាន វិមរាម

ហុច ជោគជ័យ អោយ ប្រទេសយៀកណាម។ ប្រទេសនេះ គេមាន ទស្សនៈមួយ ដែលជា យុទ្ធសាស្រ្តនយោបាយ និង យោធាផង របស់គេជានិច្ចគឺ ‹មធ្យោបាយបែបណាក៏ដោយ ដែលយកមកប្រើ ហើយវានាំឲមានជ័យជំនិះសំរាប់ជាតិ គឺជាមធ្យោបាយត្រឹមត្រូវ›។ ក្នុងទស្សនៈនេះហើយ ដែលខ្មែរយើងចេះតែនាំគ្នាឆ្ងល់ ដោយសង្កា (បារម្ភណ៍) មិនចេះចប់ ថាហេតុអ្វីបានជាខ្មែរចេះតែចាញ់បោកយួន ?

តាមសតិបញ្ញា សំនួរនេះ គឺជា សេចក្តីអស់សង្ឃឹម របស់ខ្មែរយើង នៅចំពោះមុខគ្រោះថ្នាក់ជាតិនោះឯង។ ដូចយើងឃើញថា នាបច្ចុប្បន្ននេះ អ្នកដឹកនាំ គណបក្សប្រឆាំង ដែលតាំងខ្លួន ជាអ្នកមាន សមត្ថភាពដឹកនាំជាតិ ក្នុងអនាគត ពួកគាត់នៅតែ ធ្វើនយោបាយ សរូប (ដូចសុទ្ធសាធ) នឹងអ្នកដឹកនាំ ជំនាន់មុនៗនោះឯង។ ខ្មែរយើង កុំនាំគ្នាគិតថា ពួកអ្នកដឹកនាំគណបក្សប្រឆាំង ឥតទាន់មានកំហុស ព្រោះពួកគាត់ មិនទាន់ មានអំណាច បានដឹកនាំជាតិ ចំពោះយើងវិញពួកគាត់ មានកំហុស ដោយបាន ធ្វើអន្ទង (ញ្ញុះញ្ញុង) ឲប្រជាពលរដ្ឋខ្មែរ យល់ច្រឡំ ពីសេចក្តីពិត នៃ ប្រយោជន៏ជាតិ ដូចជាការចូលរួមការបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ សំរាប់ឲយួនឈ្នះតែប៉ុណ្ណោះ។ មុសា (ភរ) នេះ ទុកស្មើនឹង បទឧក្រិដ្ឋ ព្រោះជាអំពើ សម្លាប់ជាតិ ដូចពួក ខ្មែរក្រហម ខ្មែរយួន និង យួនខ្មែរនោះដែរ។

## ការស្មានទី៣ : បើប្រជាពលរដ្ឋខ្មែរ ជាប្រជាពលរដ្ឋ មានការទទួលខុសត្រូវលើជោគវាសនា របស់ខ្លួនឯង :

ក្នុងលក្ខណៈនេះ យើងអាច ទុក ថ្ងៃ៧ មករា ជាដំណាក់ចុងក្រោយ នៃ ការលះបង់សិទ្ធិខ្លួន ជាប្រជាពលរដ្ឋ ឲយួនកុម្មុយនិស្ត ហើយ សុខចិត្ត ទទួល ថ្ងៃ ដ៏ចង្រៃនេះ ជាកម្មផល របស់ខ្លួន តាមកន្លោងធម៌ របស់ព្រះពុទ្ធសាសនា ក្នុងគោលការណ៏ ‹បុណ្យបាប›។ ការបោះបង់សិទ្ធិខ្លួន ជាប្រជាពលរដ្ឋ យើងឃើញមាន ជាក់ស្តែង ក្នុងរបបខ្មែរក្រហម គឺខ្មែរយើងពេញមួយនគរ គាត់ សុខចិត្ត ឲពួកខ្មែរក្រហម បង្អត់បាយគាត់ ចងគាត់យកទៅសម្លាប់ យ៉ាងងាយស្រួល ដូចបសុសត្វ។ ពួកខ្មែរក្រហម បង្ខំ ឲ លោកសង្ឃ ចាកសិក្ខា ដុតបំផ្លាញវត្ត ដោយគ្មានឃើញមាន ប្រតិកម្មអ្វីបប្តិចនោះឡើយ ក្នុងឋានៈខ្មែរយើង ជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយ ធ្លាប់បាន ធ្វើសច្ចាប្រណិធានថា យើងនឹងនាំគ្នា ការពារពុទ្ធសាសនា រហូតហ៊ាន បូជាជីវិតខ្លួន។ អកម្មភាពនេះ គឺនៅមាន រហូតមកដល់សព្វថ្ងៃនេះ ខ្មែរឃើញជនជាតិយួន មកនៅពេញស្រុក តែយើងមិនដែល សំដែង នូវការមិនពេញចិត្ត របស់ខ្លួនណាមួយ ដែលមាន តម្លៃ ជាកម្លាំងនយោបាយ ធ្វើសម្ពាតទៅលើរដ្ឋាភិបាល អាយ៉ងយួន ឲកែនយោបាយខ្លួន ដើម្បី ការពារ នូវ អធិបតេយ្យភាពជាតិនោះឡើយ។ ក្នុងចំណុចនេះ យើងអាចទាយទុកបានថា ថ្ងៃ៧ មករា មិនមែន ជាថ្ងៃ តែមួយថ្ងៃគត់ នៃ ការបាត់បង់ នៃ

អធិបតេយ្យភាពជាតិនោះទេ ថ្ងៃ៧ មករា ជាអតិសុខុមប្រាណ ជាកិច្ចា (ដែលមើលមិនជា) របស់ជាតិខ្មែរតែម្តង។

អស់រយះពេលជាង ៣ទសវត្ស (១៩៧៩-២០១២) រួចមកហើយ ដែលប្រទេសខ្មែរ រស់នៅក្រោមនឹម យៀកណាមកុម្មុយនិស្ត ក្នុងចន្លោះពេលនេះដែរ ខ្មែរយើង ទុកពេលវេលា គ្រប់គ្រាន់ ឲ យៀកណាម រំលាយ គំនិតការតស៊ូខ្មែរ អស់រលេញ សព្វថ្ងៃនៅ សល់តែ គំនិត រក រន្តិភាព (bonheur, plaisir) ដើម្បី អាត្មា ក្នុង សន្តិភាពមួយ ដែលជា រណ្តៅ មរណា សំរាប់កប់ប្រជាជាតិខ្មែរ។ យើងនិយាយនេះ គ្មានគំនិត ជាអ្នកសង្គ្រាមនិយម ឬ អ្នក ជាតិនិយមជ្រុលនោះឡើយ ព្រោះយើង ដឹកច្បាស់ណាស់ថា បើ មានសង្គ្រាមផ្ទុះ នៅស្រុកខ្មែរម្តងទៀត គឺជាឱកាសមួយទៀត សំរាប់យៀកណាម ប្រើខ្មែរយើង ឲសម្លាប់ខ្មែរគ្នាឯងយ៉ាងងាយ ស្រួល ដើម្បីជា អាហារ សំរាប់ចិញ្ចឹម មហិច្ឆិតា នៃ ការពង្រីក ដែនដីរបស់គេ ឲរិតតែបាន រហ័សទៅទៀត។ យៀកណាម គេ មានការពិសោធន៍ ប្រកបដោយជោគជ័យ នៃ នយោបាយ លេបកម្ពុជា។ ក្នុងការពិសោធន៏នោះ គេបង្កើតបានជា ទ្រឹស្តី មួយ ដែលគេទុកជា រូបមន្តមួយ ដ៏ស័ក្តិសិទ្ធិ សំរាប់យកមកប្រើ ដើម្បី លេបទឹកដីខ្មែរកណ្តាល បន្តទៀត។ រូបមន្តនោះ គឺគេ ទាញមកពីការប្រមាន របស់ចាស់បុរាណខ្មែរ ដែលមាន សេចក្តី ដូចនេះ ‹ខ្មែរសុនទ្រុន មិនដែល ចោលចែចូវ (ក្នុងន័យ ជា មនុស្ស ដែលប្រព្រឹត្តខាងញុះញង់) យួន មិនដែលចោល ពុត›។

សាម្នាវាចានេះ កើតមកពី ការសង្កេត ដែលមានន័យ ដូចត ទៅ: ឃួនមិនចោលពុត ព្រោះគេឃើញថា ខ្មែរឃើមិនចោលការ ញុះញង់គ្នា ដែលជា លាភមួយ សំរាប់ គេងាយស្រួលបោកប្រាស់ ខ្មែរ។ ការចាញ់នេះ បើមួយដង ឬ ពីរដង យើងនៅអាចថា ជា ការភ្លាត់ តែបើសិនជាការចាញ់បោកនោះ វាក្លាយជា ទម្លាប់ សំរាប់ខ្មែរ គឺច្បាស់ ជាខ្មែរនៅតែសួរខ្លួនឯងថា : **តើ ថ្ងៃទី៧ មករា ជាថ្ងៃអ្វី សំរាប់ខ្មែរ ?**